រដ្ឋសភា
លេខ...646...
ថ្ងៃទី...3...11...ម៉ោង...
បញ្ជូនទៅ...

# ព្រះរាជក្រម

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

* * * * * * * * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៩៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត.០៨៩៧.១៥៧ ចុះថ្ងៃទី ៧ ខែសីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦.១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស.រកម.០១៩៦.២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខជស.រកម.០១៩៨.០១ ចុះថ្ងៃទី៩ ខែមករា ឆ្នាំ១៩៩៨ ស្តីពី ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៨
- បានឃើញព្រះរាជក្រមលេខ នស.រកម១២៩៧.០៤ ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ ០១ នស ៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីឯកឧត្តមនាយករដ្ឋមន្ត្រីទី១ និងសម្តេចនាយករដ្ឋមន្ត្រីទី២ និងអំពីទេសរដ្ឋមន្ត្រី ទទួលបន្ទុកទីតិសម្បាក និងអភិវឌ្ឍន៍ និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ប្រកាសអោយប្រើ

ច្បាប់ស្តីពីការបង្កើតគណនីពិសេសរបស់ធនាគារជាតិ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី២ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១១ ខែមិនា ឆ្នាំ១៩៩៨ នាសម័យប្រជុំលើកទី៨ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

# ច្បាប់

# ស្តីពី

# ការបង្កើតគណនីពិសេសរបស់ធនាគារជាតិ

# សំរាប់

# ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

# ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបើកនៅក្នុងលេខនានៃធនាគារជាតិនូវគណនីពិសេសមួយមានឈ្មោះថា គណនីពិសេសរបស់ធនាគារជាតិសំរាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ គណនីពិសេសនេះ កត់ត្រានូវមូលនិធិទាយជ្ជទានការបោះឆ្នោត សំរាប់ឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតយកទៅចាត់ចែងក្នុងកិច្ចការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

**មាត្រា ២.-**

ធនធានទាំងឡាយនៃគណនីពិសេសនេះបានមកពី :

- ទាយជ្ជទាននៃថវិកាជាតិ
- អំណោយទានរបស់សហគមន៍អន្តរជាតិ
- ចំណូលស្របច្បាប់ផ្សេងៗទៀត ។

**មាត្រា ៣.-**

ធនធានទាំងឡាយនៃគណនីពិសេសនេះត្រូវបានប្រើប្រាស់ដើម្បីធានាដល់ចំណាយទាំងឡាយក្នុងការចាត់ចែងកិច្ចការបោះឆ្នោត រួមទាំងចំណាយសម្រាប់ប្រាក់បៀវត្សនិងប្រាក់ឧបត្ថម្ភផ្សេងៗរបស់ភ្នាក់ងារដែលត្រូវជ្រើសរើសជាបណ្ដោះអាសន្នសម្រាប់កិច្ចប្រតិបត្តិការបោះឆ្នោតផង ។

**មាត្រា ៤.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវរៀបចំនូវកម្មវិធីចំណូលនិងកម្មវិធីចំណាយតាមកម្រិតធនធានដែលមាននិងត្រូវបញ្ជូនទៅរដ្ឋសភា ដោយធ្វើអត្ថបទចម្លងទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយត្រូវផ្សព្វផ្សាយជូនដំណឹងជាសាធារណៈ ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវរៀបចំធ្វើរបាយការណ៍ស្ដីពីការអនុវត្តកម្មវិធីចំណូលនិងកម្មវិធីចំណាយក្នុងរយៈពេលមិនអោយហួសពីបីខែ បន្ទាប់ពីពេលបោះឆ្នោត ។ របាយការណ៍នេះត្រូវបញ្ជូនទៅរដ្ឋសភា ដោយធ្វើអត្ថបទចម្លងទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុហើយត្រូវផ្សព្វផ្សាយជូនដំណឹងជាសាធារណៈដែរ ។

**មាត្រា ៥.-**

ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតគឺជាអាណាប័កបើមខ្សែនៃគណនីពិសេសរបស់រតនាគារជាតិសំរាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនិងត្រូវមានអាណាប័កតាមការប្រទានសិទ្ធម្នាក់ឬច្រើននាក់ជាជំនួយការដែលតែងតាំងឡើងនិងស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អាណាប័កបើមខ្សែផ្ទាល់ ។

កិច្ចប្រតិបត្តិការនៃគណនីពិសេសរបស់រតនាគារជាតិ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវឋិតនៅក្រោមច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុនិងត្រូវអនុលោមតាមបទប្បញ្ញត្តិស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញនិងអង្គការសាធារណៈរដ្ឋបាលនិងស្តីពីលទ្ធកម្មសាធារណៈ។

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុនៃគណនីពិសេសនេះ ត្រូវចាត់តាំងឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការយល់ព្រមពីប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៦.-**

សរុបចំណាយដែលបានចុះកិច្ចសន្យាចំណាយឬបញ្ជាចំណាយលើគណនីពិសេសនេះ មិនត្រូវឱ្យលើសពីសរុបចំណូលដែលមានពិតប្រាកដនៃគណនីពិសេសនេះទេ ។

ចំណាយលើគណនីពិសេសនេះអាចបង្កើនបានតែក្នុងករណីដែលមានប្រាក់ចំណូលថ្មីនិងនៅក្នុងកម្រិតនៃប្រាក់ចំនេរទាំងនេះ ។

ហាមមិនអោយកត់ត្រាលើគណនីពិសេសនេះ នូវមុខចំណាយណាដែលមិនស្ថិតនៅក្នុងក្របខ័ណ្ឌកម្មវត្ថុរបស់ខ្លួនដូចជាប្រាក់បៀវត្សឬប្រាក់ឧបត្ថម្ភផ្សេងៗរបស់មន្ត្រីរាជការនិងភ្នាក់ងាររដ្ឋដែលត្រូវបានបើកផ្តល់ដោយថវិកាជាតិ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនិងរាជរដ្ឋាភិបាលត្រូវព្រមព្រៀងគ្នាលើការប្រើប្រាស់សមតុល្យឥណទានយីចុងបញ្ចប់នៃគណនីពិសេសនេះ ប្រសិនបើមាន ។

# ជំពូកទី ២

## មូលនិធិទាយជ្ជទាននៃថវិកាជាតិ

## សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ២

**មាត្រា ៧.-**

អនុញ្ញាតអោយផ្ទេរឥណទានចំនួនដប់ប្រាំបីពាន់លាន (១៨.០០០.០០០.០០០)រៀលពីថវិកាជាតិឆ្នាំ១៩៩៨ចូលជាមូលនិធិទាយជ្ជទាននៃឥណទានពិសេសរបស់រតនាគារជាតិសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ២ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៨ ។

# ជំពូកទី ៣

## អវសានប្បញ្ញត្តិ

**មាត្រា ៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៩.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៩៨

ក្នុងព្រះបរមនាម និង តាមព្រះរាជក្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី១ — ហត្ថលេខា — អ៊ុង ហួត

នាយករដ្ឋមន្ត្រីទី២ — ហត្ថលេខា — ហ៊ុន សែន

បានជំរាបជូន

ឯកឧត្តមនាយករដ្ឋមន្ត្រីទី១និងសម្តេចនាយករដ្ឋមន្ត្រីទី២

ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការនីតិសម្ព័ន្ធ និង

អភិវឌ្ឍន៍និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

លេខ : ចរ

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី២៣ ខែ… ឆ្នាំ១៩៩៨

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង វ៉ាន់